រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៤

## អនុក្រឹត្យលេខ ៤៦ អនក្រ
## ស្តីពីការធ្វើនិយ័តភាពថវិកាឆ្នាំ ១៩៩៤ របស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលពីជំពូក ៥១ មកបំពេញអោយជំពូក ៥២

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៤ ស្តីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុស ... ឆ្នាំ ១៩៩៤

-យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

**មាត្រា ១ :** អនុញ្ញាតអោយធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពលចំនួនទឹកប្រាក់ ៧០០.០០០.០០០រ០០ ( ប្រាំពីររយលានគត់ ) ពី ... ជំពូក ៥១ ឥណទានទទួលភារៈមកបំពេញអោយជំពូក ៥២ ប្រតិបត្តិការហិរញ្ញវត្ថុ សំរាប់ផ្តល់ជូនក្រុមហ៊ុនក្រចៅដូនទាវ ខេត្តបាត់ដំបង ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិង ថាមពល ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។